# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើស សមាជិកក្រុមប្រឹក្សាភិបាល សមាគមសហគ្រិនស្ត្រីកម្ពុជា

សមាជិកាសមាគមសហគ្រិនស្ត្រីកម្ពុជា (ស.ស.ស.ក.) ជាទីគោរពរាប់អាន!

គណៈកម្មាធិការរៀបចំការបោះឆ្នោត នៃ ស.ស.ស.ក. មានសេចក្តីសោមនស្សរីករាយ សូមគោរពអញ្ជើញសមាជិកាដាក់ពាក្យសុំចូលជាសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមនេះ សម្រាប់អាណត្តិទី៤ (ខែមេសា ២០២១ ដល់ ខែមេសា ២០២៤)។ ការបោះឆ្នោតនឹងត្រូវធ្វើឡើងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២១។ សូមកត់សម្គាល់ មានតែសមាជិក ស.ស.ស.ក. ដែលមានសុពលភាពប៉ុណ្ណោះ ដែលត្រូវបានទទួលយក។

ដើម្បីដឹកនាំ ស.ស.ស.ក. ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។ សមាជិកក្រុមប្រឹក្សាភិបាលចំនួន ១១រូប នឹងត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ដែលកើតឡើងរៀងរាល់ ៣ឆ្នាំម្តង។ សមាសភាពក្រុមប្រឹក្សាភិបាល រួមមាន ប្រធាន១រូប អនុប្រធាន ២រូប ហេរញ្ញិក ១រូប អគ្គលេខាធិការ ១រូប និងសមាជិកប្រឹក្សាភិបាល ៦រូបទៀត។ ក្រុមប្រឹក្សាភិបាល មានតួនាទីសំខាន់ក្នុងការដឹកនាំសមាគមនេះ និង សមាជិកទាំងអស់ ប្រកបដោយសិល្បៈនិងយុទ្ធសាស្ត្រ រួមទាំងជំនាញទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលអាចសម្រេចបាននូវ ចក្ខុវិស័យ និង បេសកកម្ម របស់ ស.ស.ស.ក.។

សូមចូលទៅកាន់តំណភ្ជាប់នេះ ដើម្បីអានអំពី "**លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស**" របស់ក្រុមប្រឹក្សាភិបាល និង ដើម្បីទាញយក "**ពាក្យស្នើសុំ**" នៅទីនេះ ឬអាចចូលអានព័ត៌មានលម្អិតប្រវត្តិកកើតសមាគមក្នុងគេហទំព័រ www.cweacambodia.org រួមទាំងអំណានត្រួសៗស្តីពី "**ចក្ខុវិស័យ**" និង "**បេសកកម្ម**" របស់សមាគម។

ប្រសិនបើអ្នកគិតថា គុណវុឌ្ឍិរបស់អ្នកសមនឹងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស សូមផ្ញើទម្រង់ពាក្យសុំនោះ ភ្ជាប់ជាមួយរូបថតទើបថតថ្មី ចំនួន ២សន្លឹក (ទំហំ ៤ ស.ម x ៦ ស.ម) លិខិតបញ្ជាក់ពីចំណាប់អារម្មណ៍របស់អ្នក ដែលចង់ក្លាយជាសមាជិកក្រុមប្រឹក្សាភិបាល រួមទាំងការពិពណ៌នាអំពីថា **តើបទពិសោធដឹកនាំ រួមទាំងគុណវុឌ្ឍិរបស់អ្នកឆ្លើយតបយ៉ាងដូចម្តេចដែរទៅនឹងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល។**

សូមភ្ជាប់មកជាមួយនូវឯកសារចាំបាច់ជាទម្រង់ថតចម្លង ឬ ស្កេន។ ឯកសារស្កេន សូមផ្ញើទៅកាន់ អ៊ីមែល info@cweacambodia.org ចំណែកឯកសារបោះពុម្ពលើក្រដាស សូមផ្ញើដោយផ្ទាល់ទៅកាន់ការិយាល័យកណ្តាលរបស់សមាគម ដែលមានទីតាំងស្ថិតនៅ មជ្ឈមណ្ឌលភ្នំពេញសេនធ័រ អគារ H ជាន់ទី៤ បន្ទប់លេខ ៤៨៦ មហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ។ សូមទូរស័ព្ទដោយផ្ទាល់មកកាន់លេខការិយាល័យកណ្តាល **០២៣ ២២ ៤៣ ៤៦**។ អ្នកក៏អាចរកឯកសារថតចម្លងពាក្យសុំ និងឯកសារពាក់ព័ន្ធនៅការិយាល័យ ស.ស.ស.ក. ផងដែរ។ ថ្ងៃផុតកំណត់ទទួលពាក្យសុំ គឺនៅម៉ោង **១៧:០០ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២០** ជាកំហិត។

ស.ស.ស.ក. ទន្ទឹងរង់ចាំស្វាគមន៍អ្នកដឹកនាំភេទស្រីដ៏មានសក្តានុពល និង ភាពរឹងមាំ ឈរឈ្មោះជាក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំ ស.ស.ស.ក. ឆ្ពោះទៅរកគុណប្រយោជន៍រួម ទាំងសមាជិកសមាគម និងស្ត្រីសហគ្រិននៅកម្ពុជាទាំងអស់។

សមាគមសហគ្រិនស្ត្រីកម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១១ ក្នុងគោលបំណងគាំទ្រ ដល់ការរីកចម្រើននៃអាជីវកម្មរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ន សមាជិកសមាគមនេះ បានកើនឡើងដល់ចំនួនជាង ៧០០នាក់ ដែលជាសហគ្រិនស្ត្រី និងស្ត្រីធុរកិច្ច។

មានតែបេក្ខនារី ដែលត្រូវបានជ្រើសរើសបញ្ចូលក្នុងបញ្ជីចុងក្រោយប៉ុណ្ណោះ ដែលនឹងត្រូវជូនដំណឹង!

ភ្នំពេញ ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០២០

**គណៈកម្មាធិការកិច្ចការបោះឆ្នោត**